# រឿង ឈ្មួញម្នាក់មានដើមទុនតែ ១ ហ្វូង

មាននិទានមួយថា : មានបុរសម្នាក់ទៅជួញ មានដើមទុនតែហ្វូងមួយ បានចំណេញប្រាក់មួយពាន់ ។ គ្រានោះមានបុរសកម្សត់ម្នាក់ចួនកាលមួយថ្ងៃបានហូបបាយម្តង ចួនកាល ២ ថ្ងៃបានហូបបាយម្តង សំពត់ពុំមានស្លៀក ។ ថ្ងៃ ១ មានគេឲ្យសំពត់ស្លៀក ក៏ស្លៀកសំពត់នោះដើរទៅប្របស្ទឹង ។ បុរសអ្នកជួញបានប្រាក់មួយពាន់នោះ ពុនប្រាក់និងបាយសំណុំ ដើរទៅដល់មាត់ស្ទឹងនោះគិតនឹងឆ្លង ។ ស្ទឹងនោះមានទឹកជន់ឆ្លងពុំរួច ទើបបុរសនោះនិយាយនឹងបុរសកម្សត់ថា " មិត្តអើយ ! ចម្លងអញផង អញឲ្យឈ្នួល " ។ បុរសកម្សត់ថា " អញមិនចម្លងទេព្រោះទទឹកសំពត់អញ ។ ស្តាយសំពត់ណាស់ " ។ បុរសពុនប្រាក់នោះនិយាយលោមថា " មិត្តអើយ ! បើមិត្តចម្លងអញ ៗ នឹងឲ្យឈ្នួលជាទ្រព្យសម្លាញ់ពេញចិត្ត" ។ ទើបបុរសកម្សត់នោះព្រមចម្លងបុរសពុនប្រាក់នោះរួចដល់ត្រើយ ហើយក៏ទាឈ្នួលថា "ឯណាមិត្តថាឲ្យទ្រព្យសម្លាញ់ពេញចិត្តអញនោះ ? " ។ បុរសពុនប្រាក់ថា " មានតែបាយនេះឯងជាទ្រព្យសម្លាញ់ " ។ បុរសកម្សត់ឆ្លើយថា "ចៅឯងបានមត់នឹងអញថា នឹងឲ្យទ្រព្យសម្លាញ់ដល់អញ ទើបអញចម្លងចៅ ត្បិតអញពុំដែលបានសំពត់ស្លៀក អញខ្លាចទទឹកសំពត់អញ " ។ កាលបើដូច្នោះចៅទាំង ២ នាក់ក៏នាំគ្នាទៅប្តឹងចៅក្រម ៗ ជម្រះថា " គេឲ្យបាយនោះជាទ្រព្យសម្លាញ់របស់គេហើយ គួរចៅយកបាយនោះទៅចុះ ។ បុរសកម្សត់នោះពុំព្រមយកបាយ ។ ទើបបុរសទាំង ២ នាក់នាំគ្នាទៅក្រាបបង្គំទូលព្រះមហាក្សត្រ ៗ ទ្រង់ជ្រាបដោយដំណើរនោះសព្វគ្រប់ ហើយមានព្រះបន្ទូលថា " បាយនោះទុកជាទ្រព្យសម្លាញ់ ហេតុអ្វីក៏ព្រះស្តែងមិនព្រមយក " ។ បុរសកម្សត់ក្រាបទូលថា " ខ្ញុំព្រះបាទអម្ចាស់សុំយំ " ។ ព្រះមហាក្សត្រទ្រង់សួរថា " ហេតុអ្វីក៏ព្រះស្តែងសុំយំ ? " បុរសកម្សត់ក្រាបទូលថា " សូមទ្រង់ព្រះមេត្តាប្រោស ត្បិតខ្ញុំព្រះបាទអម្ចាស់ផ្លោយគំនិត " ។ ព្រះមហាក្សត្រមានព្រះបន្ទូលថា " បើព្រះស្តែងចង់យំក៏យំតាមចិត្តព្រះស្តែងចុះ " ទើបបុរសនោះយំម្ញ៉រ ៗ ឮដល់ទៅព្រះវររាជមាតា ៗ មានព្រះសវនីយ៍ដណ្តឹងសួរថា " គេនឹងឲ្យទ្រព្យសម្លាញ់វា ឥឡូវនេះគេពុំព្រមឲ្យវា គេឲ្យឯបាយវិញ " ។ ទើបព្រះវររាជមាតា ឲ្យទៅទូលសូមយកសេចក្តីនោះអំពីព្រះរាជបុត្រមក នឹងទ្រង់ពិចារណា ។ ព្រះរាជបុត្រក៏បើកសេចក្តីនោះថ្វាយទៅសម្តេចព្រះវររាជមាតា ។ សម្តេចព្រះវររាជមាតាមានព្រះសវនីយ៍ត្រាស់ដណ្តឹងសួរបុរសទាំង ២ នាក់ថា " ហេតុអ្វីក៏ព្រះស្តែងកើតក្តីនឹងគ្នា ? " ។ បុរសទាំង ២ នាក់នោះ ក្រាបទូលតាមដំណើរទីទៃ ៗ ស្រេចហើយ ទើបសម្តេចព្រះវររាជមាតាមានព្រះសវនីយ៍ទៅបុរសពុនប្រាក់ថា " នែព្រះស្តែង ! បើទ្រព្យឯណាជាទីស្រលាញ់ពេញចិត្តព្រះស្តែង ចូរព្រះស្តែងយកទៅ ទ្រព្យឯណាព្រះស្តែង មិនស្រលាញ់ ចូរទុកនៅទីនេះចុះ " ។ បុរសនោះក្រោកឡើងដើរទៅយកតែសំពាយប្រាក់ ឯដំបងនិងបាយទុកនៅទីនោះ ។ ទើបសម្តេចព្រះវររាជមាតាមានព្រះសវនីយ៍ថា " អញប្រើព្រះស្តែងឲ្យយកទ្រព្យសម្លាញ់ ហេតុដូចម្តេចក៏ព្រះស្តែងពុំយកបាយ និងដំបងទៅផង យកតែប្រាក់ទៅ បើដូច្នេះអញយល់ថាព្រះស្តែង ទុកប្រាក់នេះជាទ្រព្យសម្លាញ់ពេញចិត្តចៅ ចូរចៅយកប្រាក់នេះមកឲ្យអញ ៗ នឹងបែងជាភាគ ចែកចៅទាំង ២ នាក់ឲ្យសុខចិត្តព្រមគ្នា កុំឲ្យតិះដៀលគ្នាទៅវិញទៅមកឡើយ " ។ ទើបសម្តេចព្រះវររាជមាតាយកប្រាក់នោះមកចែកជា ៣ ភាគ ភាគ ១ ឲ្យទៅម្ចាស់ទ្រព្យ ភាគ ២ ឲ្យទៅចៅអ្នកចម្លងនោះ ។ ចៅទាំងពីរនាក់ចូលចិត្តព្រមព្រៀងគ្នា ហើយក្រាបលាទៅកាន់ទីលំនៅទីទៃ ៗ ហោង ។